ក

មាតិកា

I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

១១-៩-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៩០៩/៨៩៩ ស្ដីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស
តាមលំដាប់ថ្នាក់ ចំពោះឯកឧត្ដម និង អស់លោក ចំនួន ១៩ រូប ៦៨៨២

១១-៩-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៩០៩/៩០០ ស្ដីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស
តាមលំដាប់ថ្នាក់ ចំពោះឯកឧត្ដម,លោកឧកញ៉ា, អស់លោក និង លោកស្រី ចំនួន ១៦ រូប ៦៨៨៣

១១-៩-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៩០៩/៩០១ ស្ដីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស
តាមលំដាប់ថ្នាក់ ចំពោះឯកឧត្ដម,ព្រះសង្ឃ, អស់លោក និង លោកស្រី ចំនួន ១៧ រូប ៦៨៨៤

១១-៩-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៩០៩/៩០២ ស្ដីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស
តាមលំដាប់ថ្នាក់ ចំពោះឯកឧត្ដម,លោកឧកញ៉ា និង អស់លោក ចំនួន ១៧ រូប ៦៨៨៥

១១-៩-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៩០៩/៩០៣ ស្ដីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស
ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះកងកម្លាំងប្រដាប់អាវុធ ចំនួន ០៤ រូប ៦៨៨៦

១១-៩-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៩០៩/៩០៤ ស្ដីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស
ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះអស់លោក ចំនួន ០៦ រូប ៦៨៨៧

១១-៩-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៩០៩/៩០៥ ស្ដីពីការតែងតាំង លោកជំទាវ ឡុង សាខន ស៊ិន សុខ
ជាឧកញ៉ា ៦៨៨៨

១១-៩-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៩០៩/៩០៦ ស្ដីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស
តាមលំដាប់ថ្នាក់ ចំពោះឯកឧត្ដម,ឧកញ៉ា ,លោកជំទាវ និង អស់លោក ចំនួន ១៣ រូប ៦៨៨៩

១២-៩-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៩០៩/៩០៧ ស្ដីពីការតម្លើងឋានន្តរស័ក្តិមន្ត្រីរាជការក្របខ័ណ្ឌមន្ត្រី
គ្រប់គ្រងរដ្ឋបាល និង មន្ត្រីបច្ចេកទេសជាន់ខ្ពស់ របស់ក្រសួង ស្ថាប័ន ចំនួន ០៧ រូប ៦៨៩០

១២-៩-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៩០៩/៩១០ ស្ដីពីការតែងតាំង ឯកឧត្ដម អ៊ុង គឹមអន ជាទីប្រឹក្សា
រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ រដ្ឋមន្ត្រី បន្ថែមលើមុខងារបច្ចុប្បន្ន ៦៨៩៣

១២-៩-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៩០៩/៩១១ ស្ដីពីការតែងតាំង ឯកឧត្ដម ចែម ទីឡា ជាទីប្រឹក្សា
រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ រដ្ឋមន្ត្រី បន្ថែមលើមុខងារបច្ចុប្បន្ន ៦៨៩៤

១២-៩-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៩០៩/៩១២ ស្ដីពីការតែងតាំង ឯកឧត្ដម ហោ ណាំបូរ៉ា ជាទីប្រឹក្សា
រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ រដ្ឋមន្ត្រី បន្ថែមលើមុខងារបច្ចុប្បន្ន ៦៨៩៥

១២-៩-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៩០៩/៩១៣ ស្តីពីការតែងតាំង ឯកឧត្តម ខៀវ ថវិកា ជាទីប្រឹក្សារាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ៦៨៩៦
១២-៩-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៩០៩/៩១៤ ស្តីពីការតែងតាំង ឯកឧត្តម ស៊ា គុសល ជាទីប្រឹក្សារាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ៦៨៩៧
១២-៩-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៩០៩/៩១៥ ស្តីពីការតែងតាំង មន្ត្រីរាជការ ចំនួន ០២ រូប ជាទីប្រឹក្សាអមក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ មានឋានៈស្មើ អគ្គនាយក ៦៨៩៨

II. រាជរដ្ឋាភិបាល

អនុក្រឹត្យ

១៥-៩-២០០៩ -អនុក្រឹត្យលេខ ១៥៤ អនក្រ.បក ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃមូលនិធិទ្រទ្រង់ និង អភិវឌ្ឍវិស័យកសិកម្ម ៦៨៩៩
១៥-៩-២០០៩ -អនុក្រឹត្យលេខ ១៥៥ អនក្រ.បក ស្តីពីនីតិវិធី នៃការផ្តល់ប្រាក់បុរេប្រទាន សំរាប់ចំណាយថវិកាចរន្ត និង ចំណាយថវិកាវិនិយោគសាធារណៈ ៦៩០៥
២៥-៨-២០០៩ -អនុក្រឹត្យលេខ ១៣៧៦ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៦៩១២
២៦-៨-២០០៩ -អនុក្រឹត្យលេខ ១៣៧៧ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៦៩១៣
២៦-៨-២០០៩ -អនុក្រឹត្យលេខ ១៣៧៨ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ៦៩១៤
២៦-៨-២០០៩ -អនុក្រឹត្យលេខ ១៣៧៩ អនក្រ.តត ស្តីពីការបន្ថែមសមាសភាពគណៈកម្មការជាតិរៀបចំគោលការណ៍ណែនាំ និង នីតិវិធីក្នុងការដឹកនាំ ការការពារសារណា និង និក្ខេបបទ ៦៩១៥
២៧-៨-២០០៩ -អនុក្រឹត្យលេខ ១៣៨០ អនក្រ.តត ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៦៩១៧
២៧-៨-២០០៩ -អនុក្រឹត្យលេខ ១៣៨១ អនក្រ.តត ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៦៩១៨
២៨-៨-២០០៩ -អនុក្រឹត្យលេខ ១៣៨២ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៦៩១៩
២៨-៨-២០០៩ -អនុក្រឹត្យលេខ ១៣៨៣ អនក្រ.តត ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាល ប្រចាំសាលាជាតិកសិកម្ម កំពង់ចាម ៦៩២០
៣១-៨-២០០៩ -អនុក្រឹត្យលេខ ១៣៨៤ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៦៩២២
០១-៩-២០០៩ -អនុក្រឹត្យលេខ ១៣៨៥ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិមន្ត្រីរាជការ ៦៩២៣
០១-៩-២០០៩ -អនុក្រឹត្យលេខ ១៣៨៦ អនក្រ.តត ស្តីពីការជូនគ្រឿងឥស្សរិយយស ៦៩២៤
០១-៩-២០០៩ -អនុក្រឹត្យលេខ ១៣៨៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៦៩២៧
០១-៩-២០០៩ -អនុក្រឹត្យលេខ ១៣៨៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៦៩២៨

០១-៩-២០០៩ -អនុក្រឹត្យលេខ ១៣៨៩ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៦៩២៩
០១-៩-២០០៩ -អនុក្រឹត្យលេខ ១៣៩០ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៦៩៣០
០១-៩-២០០៩ -អនុក្រឹត្យលេខ ១៣៩១ អនក្រ.តត ស្ដីពីការជូនមេដាយសុវត្ថារា ៦៩៣២
០១-៩-២០០៩ -អនុក្រឹត្យលេខ ១៣៩២ អនក្រ.តត ស្ដីពីការជូនមេដាយការងារ ៦៩៣៤
០១-៩-២០០៩ -អនុក្រឹត្យលេខ ១៣៩៣ អនក្រ.តត ស្ដីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៦៩៤០
០១-៩-២០០៩ -អនុក្រឹត្យលេខ ១៣៩៤ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៦៩៤១
០១-៩-២០០៩ -អនុក្រឹត្យលេខ ១៣៩៥ អនក្រ.តត ស្ដីពីការជូនមេដាយការងារ ៦៩៤២
០១-៩-២០០៩ -អនុក្រឹត្យលេខ ១៣៩៦ អនក្រ.តត ស្ដីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៦៩៤៤
០១-៩-២០០៩ -អនុក្រឹត្យលេខ ១៣៩៧ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៦៩៤៦
០១-៩-២០០៩ -អនុក្រឹត្យលេខ ១៣៩៨ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៦៩៤៩
០១-៩-២០០៩ -អនុក្រឹត្យលេខ ១៣៩៩ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៦៩៥១
០១-៩-២០០៩ -អនុក្រឹត្យលេខ ១៤០០ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៦៩៥២
០១-៩-២០០៩ -អនុក្រឹត្យលេខ ១៤០១ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៦៩៥៣
០១-៩-២០០៩ -អនុក្រឹត្យលេខ ១៤០២ អនក្រ.តត ស្ដីពីការជូនមេដាយសហមេត្រី ៦៩៥៤
០១-៩-២០០៩ -អនុក្រឹត្យលេខ ១៤០៣ អនក្រ.តត ស្ដីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៦៩៥៥
០២-៩-២០០៩ -អនុក្រឹត្យលេខ ១៤០៤ អនក្រ.តត ស្ដីពីការផ្ទេរតំណែងមន្ត្រីរាជការ ៦៩៥៦
០២-៩-២០០៩ -អនុក្រឹត្យលេខ ១៤០៥ អនក្រ.តត ស្ដីពីការតម្លើងឋានន្តរស័ក្តិជូនមន្ត្រីរាជការ ៦៩៥៨
០២-៩-២០០៩ -អនុក្រឹត្យលេខ ១៤០៦ អនក្រ.តត ស្ដីពីការជូនមេដាយការងារ ៦៩៥៩
០២-៩-២០០៩ -អនុក្រឹត្យលេខ ១៤០៧ អនក្រ.តត ស្ដីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៦៩៦០
០២-៩-២០០៩ -អនុក្រឹត្យលេខ ១៤០៨ អនក្រ.តត ស្ដីពីការតែងតាំងក្រុមប្រឹក្សាភិបាលក្រុមហ៊ុន ហ្វ្រីនគ្រេដ អាណត្តិទី ៤ ៦៩៦១
០២-៩-២០០៩ -អនុក្រឹត្យលេខ ១៤០៩ អនក្រ.តត ស្ដីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៦៩៦៣
០២-៩-២០០៩ -អនុក្រឹត្យលេខ ១៤១០ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៦៩៦៤
០២-៩-២០០៩ -អនុក្រឹត្យលេខ ១៤១១ អនក្រ.តត ស្ដីពីការជូនមេដាយការងារ ៦៩៦៥

III. ភាគទារបណ្ដាក្រសួង

ទីស្ដីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

២៣-១២-២០០៨ -លិខិតបញ្ជាក់លេខ ៦៤៨១ ពណ.ចបព ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ឌីខូខូដ អ៊ិនដាស្ទ្រី ៦៩៦៧

២៣-១២-២០០៨ -លិខិតបញ្ជាក់លេខ ៦៤៨២ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន អាល់ទេ អ៊ិនធើណេសិនណល អេនជីនា
(ខេមបូឌា) ៦៩៦៩

២៣-១២-២០០៨ -លិខិតបញ្ជាក់លេខ ៦៤៨៣ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ព៌ម្រ្គនឌីស ធីមប៊ើរ អិលធីឌី ៦៩៧១

២៣-១២-២០០៨ -លិខិតបញ្ជាក់លេខ ៦៤៩០ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន បាគខហ្គោល គ្រុប ៦៩៧៣

២៤-១២-២០០៨ -លិខិតបញ្ជាក់លេខ ៦៤៩១ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់សាខាក្រុមហ៊ុន អិល អេស ហ្វមទើត ៦៩៧៥

២៤-១២-២០០៨ -លិខិតបញ្ជាក់លេខ ៦៤៩៦ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ខេជេស៊ី ហ្វ្រីន មេឃើរ (ខេមបូឌា) ធីអិលស៊ី ៦៩៧៦

២៥-១២-២០០៨ -លិខិតបញ្ជាក់លេខ ៦៥០០ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន អាដាម៉ាស ឌីវេឡុបមេន អ៊ីន. ៦៩៧៨

២៦-១២-២០០៨ -លិខិតបញ្ជាក់លេខ ៦៥០១ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ហ្គោលដេន ហ្សរ ខូ អិលធីឌី ៦៩៨០

៣១-១២-២០០៨ -លិខិតបញ្ជាក់លេខ ៦៥១១ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន អេច ប៊ី អេច ត្រេឌីង ៦៩៨២

០២-០១-២០០៩ -លិខិតបញ្ជាក់លេខ ០០០១ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ផ្កាឈូកថ្មី ៦៩៨៤

០២-០១-២០០៩ -លិខិតបញ្ជាក់លេខ ០០០៤ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ប៊្លូ ស្តារ ឡែរ៍ ៦៩៨៦

០២-០១-២០០៩ -លិខិតបញ្ជាក់លេខ ០០០៦ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន អាតូស ស៊ីស្ទឹម ៦៩៨៨

ព្រះរាជក្រឹត្យ

យើង

នស/រកត/០៩០៩/៩៥៥

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

ក- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ
១-ឯកឧត្តម ឡៅ វណ្ណា ២-ឯកឧត្តម ស៊ុយ ច័ន្ទណារិទ្ធ

ខ- គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ
១- ឯកឧត្តម សាំង ណាន

គ- គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ សេនា ចំពោះ
១- លោក ម៉េង គិត ២- លោក ស៊ុយ សំអិត

ឃ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា ចំពោះ
១- ឯកឧត្តម តូច សុផារ៉ា ២- លោក ពន ប៊ុ
៣- លោក ពៅ ម៉េងហៃ ៤- លោក ជូ គីមត្រី
៥- លោក ជឹម ជា ៦- លោក យូ មី
៧- លោក នង គន្ធរ៉ា ៨- លោកស្រីវេជ្ជបណ្ឌិត ឌូច សុខនាង
៩- លោកវេជ្ជបណ្ឌិត គុំ សំសុង ១០- លោក ម៉ៅ សុខ្លាគុណ
១១- លោក ប៊ុន ធី ១២- លោក ឌុក វ៉ាន់ថា
១៣- លោក នាង វុទ្ធ ១៤- លោក អៀង អុននី

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៩

ក្នុងព្រះបរមនាម និងតាមព្រះរាជក្រាស់បង្គាប់

៧៧.០៩០៩.៩១៦

ប្រមុខរដ្ឋស្តីទី
ហត្ថលេខា និងព្រះរាជលញ្ឆករ
សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

លេខៈ៨៣៨ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ជិនកេន

ព្រះរាជក្រឹត្យ

យើង

នស/រកត/០៩០៩/៩០០

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី
ប្រោសព្រះរាជទាន
នូវ

ក-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ

១- ឯកឧត្តម ស៊ិន ឫទ្ធី
២- លោកឧកញ៉ា រ៉ឹង សីហេង
៣-លោកឧកញ៉ា ឆាំង ប៉េងយូ
៤-លោកឧកញ៉ា លឹម ឫទ្ធី
៥- លោកស្រី ប៉ុន. ដានី
៦- Mr. TOMAS A. NORTON

ខ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ ចំពោះ

១- លោក ឃីម ច័ន្ទធី
២- លោក គាត់ ចណ្ណា
៣- លោក ចួន ម៉ុង
៤- លោក អាង ហួង
៥- លោក ហៀក ចាន់លាង
៦- លោក ហ៊ឹម គិរី
៧- លោក ខេង គេង
៨- អនុសេនីយ៍ឯក ឃីម សារ៉េណ

គ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ ចំពោះ

១- ឯកឧត្តម ទៀង តៅ
២- លោកស្រី រស់ ចាន់សោភា

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៩

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

៣៩ល.០៩០៩.៩១៧

ប្រមុខរដ្ឋស្តីទី
អគ្គលេខា និងព្រះរាជលញ្ឆករ
សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

លេខ ៧៤១ ច.ល
ជំនួសចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ២០០៩
ទីស្តីការគណៈរដ្ឋមន្ត្រី
ស៊ុន ចិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៩០៩/៩០២

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី
ប្រោសព្រះរាជទាន
នូវ

ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ

១-ឯកឧត្តម ហ៊ុន អៀង
២- ព្រះគ្រូ ហាត់ សុខគឿន

ខ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ចំពោះ

១- ឯកឧត្តមវេជ្ជបណ្ឌិត ឈួយ ម៉េង
២-ព្រះវិន័យធរ ទេព ហាត្ថា
៣- លោក ហ៊ាង គង់ផេង
៤- លោក សេង ឫទ្ធី
៥- លោក លាង អ៊ួក

គ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ ចំពោះ

១- លោក ឃិន សីហា
២- លោក ប៉ោ យូលីន
៣- លោក ទូយ ហោ
៤- លោក សាន់ សុផល
៥- លោក សេង ឡេង
៦- លោកស្រី សេង ចាន់បូរ
៧- លោកស្រី មាស ម៉ានី
៨- លោកស្រី ឃិន ស៊ីថន
៩- លោកស្រី ហ៊ីន ធានី
១០- លោក អ៊ឹម គឹមអៀន

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០០៩

ក្នុងព្រះបរមនាម និងតាមព្រះរាជឱង្ការបន្ទាប់

ប្រមុខរដ្ឋស្តីទី
ហត្ថលេខា និងព្រះរាជលញ្ឆករ
សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

៣រ.ល.០៩០៩.៩១៧

ថ្ងៃ [illegible] ច.ស
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ២០០៩
[illegible]រាជរដ្ឋាភិបាល
[illegible] ចិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៩០៩/៩០២

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី
ប្រោសព្រះរាជទាន
ជូន

ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ

១- លោកឧកញ៉ា តាំង ឆេងប៉ោ
២- លោកឧកញ៉ា អ៊ុន យុទ្ធី
៣- វរសេនីយ៍ត្រី លឹម ឃេង
៤- ឯកឧត្តម សាន សំបូរី

ខ-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ

១- ឯកឧត្តម ម៉ក់ ពេជ្ររិទ្ធ
២- ឯកឧត្តម ទៀវ ខែម
៣-លោក ឈឹម គន
៤- ឯកឧត្តម ផៃ អ៊ុនឈឿន

គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ចំពោះ

១- ឯកឧត្តម ឃឹង សារ៉ាត់
២- ឯកឧត្តម អ៊ុក សាវុធ
៣- ព្រឹទ្ធាចារ្យ មោគ ស៊ីម
៤- លោក អេន សំអុល
៥- លោក ហ៊ាន់ គឹមស្រ៊ុន
៦- លោក ហ៊ួច ពុទ្ធារិទ្ធ
៧- លោក សួខ សុជាតា
៨- លោក អេម ធីម៉ង់
៩- លោក ឯក ឃុនធឿន

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៩

ក្នុងព្រះបរមនាម និងតាមព្រះរាជគ្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី
ហត្ថលេខា និងព្រះរាជលញ្ឆករ
សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

៣/៧.០៩០៩.៩២៩

លេខ:៨៤០ច.ល
រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ២០០៩

ព្រះរាជក្រឹត្យ

យើង

នស/រកត/០៩០៩/៩០៣

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពោហនាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ ចំពោះ :-

១-វរសេនីយ៍ឯក អ៊ុច ចន្ធី 00២៧៧៣

២-វរសេនីយ៍ទោ ឈរ ណារ៉ែត 00៨៧៦៨

ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ ចំពោះ :-

១-វរសេនីយ៍ត្រី អ៊ុក ហឿនពិសី 0៣0១១៧

២-វរសេនិយ៍ត្រី អ៊ុក ហឿនពណ្ណរាយ 0៣0៦១៨

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៩

ក្នុងព្រះបរមនាម និងតាមព្រះរាជបន្ទូលបង្គាប់

៣រល.០៩០៩.៩២០

ប្រមុខរដ្ឋស្តីទី
ហត្ថលេខា និងព្រះរាជលញ្ឆករ
សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

លេខៈ [illegible] ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

[illegible] ឌិនកេន

ព្រះរាជក្រឹត្យ

យើង

នស/រកត/០៩០៩/៩០៤

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ទូវ

ក- គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ ចំពោះ :-

១- លោក យូ គិរម្យ ២- លោក វ័ន្ត សុភះ

ខ- គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា ចំពោះ :-

១- លោក ឆាយ ត្រលន់ ២- លោក ទូម ចាន់តន្នី

គ- គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ ចំពោះ :-

១- លោក និត្យ ចន្ទ ២- លោក គីម សំអាត

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៩

ក្នុងព្រះបរមនាម និងតាមព្រះរាជបន្ទូលបង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

៣រល.០៩០៩.៩៤១

លេខៈ ៨៤៧ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០០៩

អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល

ស៊ុន ចិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៩០៩/៩០៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

តែងតាំង

លោកជំទាវ ឡុង សាខន ស៊ិន សួង

ជា

ឧកញ៉ា

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៩

ភ្នំពេញព្រះបរមនាម និងតាមព្រះរាជក្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី
ហត្ថលេខា និងព្រះរាជលញ្ចករ
សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

៣៩ល.០៩០៩.៩៤៤

លេខ:៨៤៦ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៩
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជក្រឹត្យ

យើង

នស/រកត/០៩០៩/៩០៦

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ព្រះរាជទាន

ជូន

ក. គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ :

១- ឯកឧត្តម សុខ ផល ២- ឯកឧត្តម វៃ ស៊ីណារិទ្ធ

ខ. គ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ ថ្នាក់មហាសេរីវឌ្ឍន៍ ចំពោះ :

-ឯកឧត្តមឧកញ៉ា ងីម សាវុធ

គ. គ្រឿងឥស្សរិយយសសុវត្ថារា ថ្នាក់មហាសេនា ចំពោះ :

១- ឯកឧត្តម ស៊ាង ប៊ុនលាង ៦-លោក សឿម ប៊ុនរិទ្ធ
២- ឯកឧត្តម អ៊ុច សុមុន ៧-លោក អ៊ុយ សុធាវី
៣-ឯកឧត្តម ឃិត ស្ទួច ៨- លោកជំទាវ គីម ហេង
៤- លោក ហាស់ រ៉េម៉ងឡុង ៩- លោកជំទាវ ហ៊ុន ប៊ុនធឿន
៥-លោក សៀង ឃុជាក័ត់ ១០- លោក ផាង ពៅ

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០៩
ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី
ហត្ថលេខា និងព្រះរាជលញ្ឆករ
សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

៣៧ល. ០៩០៩. ៩៤៣

លេខ ៨៤៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៩
[illegible] រាជរដ្ឋាភិបាល

ស៊ុន ចិនកេន

ព្រះរាជក្រឹត្យ

យើង

នស/រកត/០៩០៩/៩០៧

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពី លក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥១ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានដំឡើងឋានន្តរស័ក្តិមន្ត្រីរាជការក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាលរបស់ក្រសួង ស្ថាប័ន ចំនួន ០៦ រូប ដូចមានរាយនាមខាងក្រោម :

ក្រសួងសាធារណការ និងដឹកជញ្ជូន				
១	ម៉ែន មាណាទី	ស	ពីវរមន្ត្រី ថ្នាក់លេខ ៣	ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៤
២	មាស ម៉ូនីកា	ប	ពីវរមន្ត្រី ថ្នាក់លេខ ៣	ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៤
ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា				
១	ឡៀង សុគន្ធ	ប	ពីវរមន្ត្រី ថ្នាក់លេខ ៤	ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៥
ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់				
១	លឹម ហោ	ប	ពីវរមន្ត្រី ថ្នាក់លេខ ៤	ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៥
ក្រសួងអភិវឌ្ឍន៍ជនបទ				
១	ជា សំណាង	ប	ពីវរមន្ត្រី ថ្នាក់លេខ ៣	ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៤
ក្រសួងបរិស្ថាន				
១	ឈុន ប៊ុនលី	ប	ពីវរមន្ត្រី ថ្នាក់លេខ ៧	ទៅឧត្តមមន្ត្រី ថ្នាក់លេខ ៦

មាត្រា ២ : ត្រូវបានដំឡើងឋានន្តរស័ក្តិមន្ត្រីរាជការក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ របស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ចំនួន ០១ រូប ដូចមាននាមខាងក្រោម :

១	ជា អូន	ប	ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ដើមខ្សែ ថ្នាក់លេខ ៦	ទៅមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ដើមខ្សែពិសេស ថ្នាក់លេខ ៦

មាត្រា ៣ : មន្ត្រីដែលត្រូវបានដំឡើងឋានន្តរស័ក្តិដូចមានឈ្មោះក្នុងមាត្រា ១ និងមាត្រា ២ ខាងលើត្រូវរក្សាទុកអតីតភាព

ROYAUME DU CAMBODGE · MINISTERE DU PALAIS ROYAL · ក្រសួងព្រះបរមរាជវាំង

សម្រាប់ឡើងថ្នាក់តាមវេនជ្រើសរើស និងវេនអតីតភាពដដែល ។

មាត្រា ៤ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៥ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៦ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០០៩

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម

នសរ. ០៩០៩. ៩២៨

លេខៈ ៨៥០ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ២០០៩

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៩០៩/៩៦០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានតែងតាំង ឯកឧត្តម **អ៊ុំ គឹមអន** ជាទីប្រឹក្សារាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ **រដ្ឋមន្ត្រី** បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០០៩

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

រ.ល.០៩០៩.៩២៧

ប្រមុខរដ្ឋស្តីទី
ហត្ថលេខា និងព្រះរាជលញ្ឆករ
ជា ស៊ីម

ច.ល
ថតចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ២០០៩
ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៩០៩/៩១១

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានតែងតាំង ឯកឧត្តម **ចែម វីឌ្យា** ជាទីប្រឹក្សារាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ **រដ្ឋមន្ត្រី** បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០០៩

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

៣រល.០៩០៩.៩២៧

ប្រមុខរដ្ឋស្តីទី
ហត្ថលេខា និងព្រះរាជលញ្ឆករ
ជា ស៊ីម

ច.ល
ដើម្បីចម្លងចែក
ភ្នំពេញ ... ខែកញ្ញា ឆ្នាំ២០០៩
...រាជរដ្ឋាភិបាល

ព្រះរាជក្រឹត្យ

នស/រកត/០៩០៩/៩៦២

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានតែងតាំង ឯកឧត្តម **ហោ ណាំបូរ៉ា** ជាទីប្រឹក្សារាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ រដ្ឋមន្ត្រី បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០០៩

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

៣រល.០៩០៩.៩២៩

ប្រមុខរដ្ឋស្តីទី
ហត្ថលេខា និងព្រះរាជលញ្ឆករ
ជា ស៊ីម

លេខ ៨៥៦ច.ល
ដើម្បីចម្លងចែក
ខែ កញ្ញា ឆ្នាំ២០០៩
ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៩០៩/៩៦៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានតែងតាំង ឯកឧត្តម **ខៀវ ថវិកា** ជាទីប្រឹក្សារាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០០៩

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

៣រល.០៩០៩.៩៣០

លេខ ៧៥៥ ច.ល

ខែកញ្ញា ឆ្នាំ២០០៩

ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/០៩០៩/៩៦៨

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ត្រូវបានតែងតាំង ឯកឧត្តម ស៊ា គុសល ជាទីប្រឹក្សារាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ រដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០០៩

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

៣៩ល.០៩០៩.៩៣១

ច.ល
ដើម្បីចម្លងចែក
ខែ កញ្ញា ឆ្នាំ២០០៩

ព្រះរាជក្រឹត្យ

នស/រកត/០៩០៩/៩៦៥

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : តែងតាំងមន្ត្រីរាជការ ចំនួន ០២ រូប ជាទីប្រឹក្សាអមក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ មានឋានៈស្មើ **អគ្គនាយក** ដូចមានរាយនាមខាងក្រោម :

១-ឯកឧត្ដម **ញ៉ែ សុន្ធរ**

២-ឯកឧត្ដម **ញាន ស្រស់**

មាត្រា២ : បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

មាត្រា៣ : សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា៤ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០០៩

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្ដីទី
ហត្ថលេខា និងព្រះរាជលញ្ឆករ
ជា ស៊ីម

៣រល.០៩០៩.៩៣២

លេខ: ៨៤៥ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ប៊ិនកេន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ..១៥៤..អនក្រ-បក

អនុក្រឹត្យ
ស្តីពី
ការរៀបចំ និងការប្រព្រឹត្តទៅនៃ មូលនិធិទ្រទ្រង់ និងអភិវឌ្ឍវិស័យកសិកម្ម

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែតុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៨/០២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៩ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៩
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សម្រេច

ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

មាត្រា ១.- គោលបំណង

អនុក្រឹត្យនេះមានគោលបំណងកំណត់ពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិទ្រទ្រង់ និងអភិវឌ្ឍវិស័យកសិកម្ម ។

មាត្រា ២.- គោលដៅ

អនុក្រឹត្យនេះ មានគោលដៅកំណត់ក្របខ័ណ្ឌគតិយុត្តសម្រាប់ផ្តល់ឥណទានរយៈពេលខ្លី មធ្យម និងវែង ដល់សមាគម សហគមន៍ ឬក្រុមហ៊ុន ដើម្បីជួយទ្រទ្រង់ និងអភិវឌ្ឍវិស័យកសិកម្ម និងកសិ-ឧស្សាហកម្ម ។

មាត្រា ៣.- វិសាលភាព

អនុក្រឹត្យនេះ មានវិសាលភាពគ្របដណ្តប់លើការគ្រប់គ្រងមូលនិធិទ្រទ្រង់ និងអភិវឌ្ឍវិស័យកសិកម្ម ដែលជាកម្មវិធីពិសេសរបស់រាជរដ្ឋាភិបាល ក្នុងការផ្តល់ឥណទានចំពោះសកម្មភាពជាអាទិភាពដូចតទៅ :

១-ផ្តល់ឥណទានរយៈពេលខ្លី ដល់សមាគម សហគមន៍ ឬក្រុមហ៊ុន សម្រាប់ការប្រមូលទិញស្រូវ-អង្ករ កសិផល និងអនុផលផ្សេងទៀតពីកសិករតាមតម្លៃមួយសមរម្យ ដើម្បីធានាស្ថិរភាពថ្លៃ និងសន្តិសុខស្បៀង ។

២-ផ្តល់ឥណទានរយៈពេលមធ្យម និងវែងដល់សមាគម សហគមន៍ ឬ ក្រុមហ៊ុនកែច្នៃស្រូវ-អង្ករ កសិផល និងអនុផលផ្សេងទៀត សម្រាប់ពង្រីកសមត្ថភាពឃ្លាំងស្តុក ម៉ាស៊ីនសម្ងួត និងម៉ាស៊ីនកែច្នៃទំនើប ដើម្បីពង្រឹងសមត្ថភាព និងគុណភាពកែច្នៃផលិតផលកសិកម្មដែលបម្រើសេចក្តីត្រូវការក្នុងស្រុក និងការនាំចេញ ។

៣-ផ្តល់ឥណទានរយៈពេលមធ្យម និងវែងដល់សមាគម សហគមន៍ ឬ ក្រុមហ៊ុនក្នុងគោលដៅអភិវឌ្ឍអនុវិស័យផ្សេងៗ ក្នុងវិស័យកសិកម្ម និងកសិ-ឧស្សាហកម្ម ។

មាត្រា ៤.- និយមន័យ

"សហគមន៍ ឬសមាគម" សំដៅដល់នីតិបុគ្គលដែលបានចុះបញ្ជីត្រឹមត្រូវតាមបទប្បញ្ញត្តិជាធរមាន នៅស្ថាប័នមានសមត្ថកិច្ច និងធ្វើសកម្មភាពក្នុងវិស័យកសិកម្ម ឬកសិ-ឧស្សាហកម្ម ។

"ក្រុមហ៊ុន" សំដៅដល់នីតិបុគ្គលដែលបានចុះបញ្ជីត្រឹមត្រូវតាមច្បាប់នៅក្រសួងពាណិជ្ជកម្ម ហើយធ្វើសកម្មភាពចម្បង ឬសកម្មភាពគាំទ្រក្នុងវិស័យកសិកម្ម ឬ កសិ-ឧស្សាហកម្ម ដែលមានជាអាទិ៍ ផលិតកម្មដំណាំស្រូវ ដំណាំអនុផល ការកែច្នៃស្រូវ-អង្ករ និងអនុផលផ្សេងៗ ការចិញ្ចឹមសត្វ និងមច្ឆាវប្បកម្ម ។

"រយៈពេលខ្លី" សំដៅដល់រយៈពេលដែលមិនលើសពី ១ (មួយ)ឆ្នាំ ។

"រយៈពេលមធ្យម"សំដៅដល់រយៈពេលដែលលើសពី ១(មួយ) ឆ្នាំ និងមិនលើសពី ៣(បី) ឆ្នាំ ។

"រយៈពេលវែង" សំដៅដល់រយៈពេលដែលលើសពី ៣(បី) ឆ្នាំ ឡើងទៅ ។

ជំពូកទី ២

មេធាសម្ព័ន្ធគ្រប់គ្រង

មាត្រា ៥.- ក្រុមប្រឹក្សាគោលនយោបាយ

មូលនិធិទ្រទ្រង់ និងអភិវឌ្ឍវិស័យកសិកម្ម ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបង្កើតក្រុមប្រឹក្សាគោលនយោបាយមួយ ដែលមានតួនាទីកំណត់គោលនយោបាយក្នុងការប្រើប្រាស់ឥណទានសម្រាប់ជួយទ្រទ្រង់ និងអភិវឌ្ឍវិស័យកសិកម្ម ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ។

សមាសភាពក្រុមប្រឹក្សាគោលនយោបាយមានដូចខាងក្រោម ៖

១-រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	ប្រធាន
២-ប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ	អនុប្រធាន
៣-តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	សមាជិក
៤-តំណាងក្រសួងអភិវឌ្ឍន៍ជនបទ	សមាជិក
៥-តំណាងវិស័យឯកជនក្នុងវិស័យកសិកម្ម	សមាជិក
៦-ប្រធាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ	លេខាធិការ

ការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រុមប្រឹក្សាគោលនយោបាយ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ប្រធានក្រុមប្រឹក្សាគោលនយោបាយ មានសិទ្ធិអញ្ជើញតំណាងក្រសួង-ស្ថាប័នផ្សេង

ទៀតចូលរួមពិភាក្សាការងារតាមការចាំបាច់ ។

មាត្រា ៦.- គណៈកម្មការឥណទាន

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបង្កើតគណៈកម្មការឥណទានមួយ ដើម្បីអនុវត្តគោលនយោបាយកំណត់ដោយក្រុមប្រឹក្សាគោលនយោបាយ ។ គណៈកម្មការឥណទាននេះមានភារកិច្ចវាយតម្លៃ អនុម័តគម្រោង និងត្រួតពិនិត្យការអនុវត្តគម្រោងឥណទាន ក្នុងក្របខណ្ឌមូលនិធិទ្រទ្រង់ និងអភិវឌ្ឍវិស័យកសិកម្ម ។

គណៈកម្មការឥណទាន ត្រូវលើកសំណើសុំផ្តល់ឥណទានដល់គម្រោង ដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ពិនិត្យ និងសម្រេច។

គណៈកម្មការឥណទានមានសមាសភាពដូចខាងក្រោម :

១- ប្រធានអគ្គនាយកធនាគារអភិវឌ្ឍន៍ជនបទ ជាប្រធាន

២- ប្រធាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ អនុប្រធាន

៣- តំណាងធនាគារអភិវឌ្ឍជនបទ ០២ រូប សមាជិក

៤- មន្ត្រីជំនាញនៃនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ០១ រូប សមាជិក ។

ការរៀបចំ និងការប្រព្រឹត្តទៅ របស់គណៈកម្មការឥណទាន ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

នីតិវិធីនៃការស្នើសុំ និងអនុម័តផ្តល់ឥណទាន ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មាត្រា ៧.- ស្ថាប័នអនុវត្ត

ធនាគារអភិវឌ្ឍន៍ជនបទ គឺជាស្ថាប័នគ្រប់គ្រងការអនុវត្តគម្រោងឥណទាន ដែលត្រូវបានអនុម័តដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

មាត្រា ៨.- ការរៀបចំរបាយការណ៍

ធនាគារអភិវឌ្ឍន៍ជនបទ និងគណៈកម្មការឥណទាន ត្រូវធ្វើរបាយការណ៍នៃការប្រើប្រាស់ឥណទានជាទៀងទាត់ និងតាមការចាំបាច់ ជូនក្រុមប្រឹក្សាគោលនយោបាយ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវរាយការណ៍តាមការចាំបាច់ ជូនរាជរដ្ឋាភិបាល អំពីការប្រើប្រាស់មូលនិធិទ្រទ្រង់ និងអភិវឌ្ឍវិស័យកសិកម្ម ។

ជំពូកទី ៣

ប្រភពធនធាន និងការប្រាក់

មាត្រា ៩.- ប្រភពធនធាន

ប្រភពធនធាននៃមូលនិធិទ្រទ្រង់ និងអភិវឌ្ឍវិស័យកសិកម្ម រួមមាន :

- ធនធានដំបូងជាឥណទានពិសេសចំនួន ៧២,០០០,០០០,០០០៛ (ចិតសិបពីរ-ពាន់លានរៀល) ដែលកំណត់ដោយច្បាប់ស្តីពីការកែតម្រូវនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៩
- ធនធានបន្ថែមពីប្រភពថវិកាជាតិ ទៅតាមការចាំបាច់របស់រាជរដ្ឋាភិបាល
- ការចូលរួមវិភាគទានពីដៃគូអភិវឌ្ឍន៍ និង
- ប្រភពផ្សេងទៀត ។

មាត្រា ១០.- ការប្រាក់

ការផ្តល់ឥណទាន ត្រូវកំណត់អត្រាការប្រាក់មិនខ្ពស់ជាងអត្រាការប្រាក់របស់ធនាគារពាណិជ្ជនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ អត្រាការប្រាក់នៃឥណទាននេះត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ការប្រាក់ដែលទទួលបានមកពីការផ្តល់ហិរញ្ញប្បទាននេះ ត្រូវយកទៅប្រើប្រាស់សម្រាប់ការគ្រប់គ្រងប្រតិបត្តិការនៃការផ្តល់ឥណទាន និងការបង្កើនមូលនិធិទ្រទ្រង់ និងអភិវឌ្ឍវិស័យកសិកម្ម តាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ជំពូកទី ៤

ទោសប្បញ្ញត្តិ

មាត្រា ១១.- ទោសប្បញ្ញត្តិ

មន្ត្រីសាធារណៈទាំងឡាយណា ដែលត្រូវបានរកឃើញថាមិនបានគោរពតាមបទ-ប្បញ្ញត្តិនៃអនុក្រឹត្យនេះ ដោយការអនុវត្តមុខងារ និងភារកិច្ចរបស់ខ្លួនចំពោះការគ្រប់គ្រង ឬការប្រើប្រាស់មូលនិធិក្នុងស្ថានភាពមិនសមស្រប និងធ្វើឱ្យបាត់បង់ដោយប្រការណាមួយតាមរយៈការលួចកិបកេង ក្លែងបន្លំ ឬ ប្រើប្រាស់មូលនិធិនេះខុសគោលដៅ ត្រូវទទួលទណ្ឌ-កម្មខាងវិន័យទៅតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមានដោយមិនទាន់គិតដល់ទណ្ឌកម្មព្រហ្មទណ្ឌ និងការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីផ្សេងទៀត ។

ជំពូកទី ៥

អវសានប្បញ្ញត្តិ

មាត្រា ១២.- និរាករណ៍

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

មាត្រា ១៣.- ការអនុវត្ត

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី ប្រធាន គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៩

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

<u>កន្លែងទទួល:</u>
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១៣ "ដើម្បីអនុវត្ត"
-រាជកិច្ច ✓
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៥៥ អនក្រ.បក

អនុក្រឹត្យ
ស្តីពីនីតិវិធីនៃការផ្តល់ប្រាក់បុរេប្រទាន
សម្រាប់ចំណាយថវិកាចរន្ត និងចំណាយថវិកាវិនិយោគសាធារណៈ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥, ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤, ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨, ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦, ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក, ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក, ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើចំណាយរដ្ឋបាលនៅតាមក្រសួង ខេត្ត-ក្រុង ក្រុងស្វយ័ត រាជធានីភ្នំពេញ និងអង្គភាពសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក, ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ស្តីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក, ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៧ ស្តីពីការដាក់ឱ្យប្រើប្រាស់នូវនីតិវិធីរួម សម្រាប់អនុវត្តគម្រោងហិរញ្ញប្បទានដោយធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សម្រេច

ជំពូកទី ១
បទប្បញ្ញត្តិទូទៅ

មាត្រា១.

អនុក្រឹត្យនេះមានគោលដៅកំណត់នូវគោលការណ៍ និងនីតិវិធីនៃការអនុវត្តកិច្ចប្រតិបត្តិការចំណាយថវិការដ្ឋ តាមរយៈការផ្តល់ប្រាក់បុរេប្រទាននៅក្នុងក្របខ័ណ្ឌចំណាយថវិកាចរន្ត និងចំណាយថវិកាវិនិយោគសាធារណៈ ។

មាត្រា២.

អនុក្រឹត្យនេះមានគោលបំណងដើម្បីឱ្យអាណាប័កក្រសួង ស្ថាប័ន ÷

- ពង្រឹងការគ្រប់គ្រងចំណាយប្រាក់បុរេប្រទាន ឱ្យប្រកបដោយតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាព
- យកចិត្តទុកដាក់ក្នុងការធ្វើនិយ័តកម្ម (ការទូទាត់) ប្រាក់បុរេប្រទានឱ្យបានឆាប់រហ័ស
- កាត់បន្ថយការស្នើសុំប្រាក់បុរេប្រទាននៅក្នុងចំណាយថវិកាចរន្ត ឱ្យទៅជាការអនុវត្តចំណាយតាមនីតិវិធីហិរញ្ញវត្ថុជាធរមាន ។

មាត្រា៣.

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះគ្រប់ក្រសួង ស្ថាប័នដែលមានថវិកាកំណត់នៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ ។

ជំពូកទី ២
គោលការណ៍សំខាន់ៗនៃការផ្តល់ប្រាក់បុរេប្រទាន

មាត្រា៤.

ការផ្តល់ប្រាក់បុរេប្រទានសម្រាប់ចំណាយថវិកាចរន្ត និងចំណាយថវិកាវិនិយោគសាធារណៈ អនុវត្តសម្រាប់មុខចំណាយទាំងឡាយមានជាអាទិ៍ដូចខាងក្រោម ÷

ក. ចំណាយថវិកាចរន្ត ៖

- ចំណាយសម្រាប់ទទួលគណៈប្រតិភូបរទេស
- ចំណាយសម្រាប់ប្រជុំ សិក្ខាសាលា និងសន្និសីទ
- ចំណាយសម្រាប់ពិធីបុណ្យប្រពៃណី បុណ្យជាតិ និងអន្តរជាតិ
- ចំណាយសម្រាប់ការប្រឡងប្រជែង
- ចំណាយសម្រាប់ការបំប៉នសិស្សពូកែ និងកីឡាករ
- ចំណាយសម្រាប់ការប្រកួតកីឡា
- ចំណាយសម្រាប់សម្ភោធសមិទ្ធផលនានា
- ចំណាយជួសជុល ថែទាំហេដ្ឋារចនាសម្ព័ន្ធ ផ្លូវ ស្ពាន និងធារា,សាស្ត្រ ដែលត្រូវអនុវត្តដោយអង្គភាពរដ្ឋ

ខ. ចំណាយថវិកាវិនិយោគ ៖

- ចំណាយសម្រាប់អនុវត្តគម្រោងវិនិយោគសាធារណៈ ដែលត្រូវអនុវត្តដោយអង្គភាពរដ្ឋ ។

មាត្រា៥.

ការអនុវត្តការផ្តល់ប្រាក់បុរេប្រទានសម្រាប់មុខចំណាយទាំងឡាយដូចបានកំណត់ក្នុងមាត្រា ៤ នៃអនុក្រឹត្យនេះក្រសួង ស្ថាប័នត្រូវគោរពទៅតាមគោលការណ៍ទាំងឡាយ ដូចខាងក្រោមនេះ ៖

ក. ចំណាយថវិកាចរន្ត ៖

- ត្រូវមានឥណទានថវិកាសល់ទំនេរ សម្រាប់កាត់ទុកដើម្បីធ្វើការទូទាត់ចំណាយ
- ត្រូវលើកសំណើសុំប្រាក់បុរេប្រទាន ដោយមានភ្ជាប់មកជាមួយនូវគម្រោងចំណាយលម្អិតទៅតាមអនុគណនីនីមួយៗឱ្យបានច្បាស់លាស់ និងមានភ្ជាប់សលាកប័ត្រកត់ត្រាចំណាយថវិកា និងត្រួតពិនិត្យហិរញ្ញវត្ថុ ដើម្បីកាត់ទុកឥណទានថវិកាសម្រាប់ធ្វើអាណត្តិនិយ័តកម្ម ។
- ត្រូវធ្វើការទូទាត់ប្រាក់បុរេប្រទានលើកមុនទៅតាមពេលវេលាកំណត់សិន ទើបអាចលើកសំណើសុំប្រាក់បុរេប្រទានលើកក្រោយបាន លើកលែង

តែការចំណាយប្រាក់បុរេប្រទានលើកមុន ត្រូវប្រើពេលវេលាយូរលើសពីមួយខែឡើងទៅ ។

- ក្នុងករណីជាយថាហេតុណាមួយធ្វើឱ្យប្រាក់បុរេប្រទានឆ្នាំមុនមិនបានទូទាត់ ត្រូវកាត់ទុកឥណទានថវិកាឆ្នាំបន្ទាប់ជាមុនសិន ហើយត្រូវរៀបចំធ្វើការទូទាត់ឱ្យបានជ្រះស្រឡះមុននឹងចាប់ផ្ដើមប្រតិបត្តិការថវិកា ។
- មិនអនុញ្ញាតប្រើប្រាស់បុរេប្រទានសាច់ប្រាក់ បើគ្មានឥណទានថវិកាគ្រប់គ្រាន់ទេនោះ ។

ខ. ចំណាយថវិកាវិនិយោគ ÷

- ត្រូវអនុវត្តផ្ដល់ប្រាក់បុរេប្រទាន សម្រាប់គម្រោងក្នុងក្របខ័ណ្ឌនៃកញ្ចប់ឥណទានអនុញ្ញាតប្រចាំឆ្នាំ ។ ក្នុងករណីការអនុវត្តគម្រោង ឬការបំពេញនីតិវិធីសម្រាប់គម្រោងមានការយឺតយ៉ាវ ដែលធ្វើឱ្យការទូទាត់បុរេប្រទានមិនអាចធ្វើទាន់ក្នុងឆ្នាំ ត្រូវកាត់ទុកឥណទានថវិកាឆ្នាំបន្ទាប់ដើម្បីធ្វើការទូទាត់ស្មើនឹងទឹកប្រាក់មិនទាន់ទូទាត់នៃគម្រោងទាំងមូល ។
- ត្រូវមានភ្ជាប់មកជាមួយសំណើសុំបុរេប្រទាន នូវគម្រោងចំណាយលម្អិត លើកលែងតែក្នុងករណីចាំបាច់ត្រូវអនុវត្តបន្ទាន់ តាមការសម្រេចរបស់នាយករដ្ឋមន្ត្រី ដែលគម្រោងចំណាយលម្អិតមិនអាចធ្វើបានភ្លាមៗដោយសារស្ថានភាពទីតាំង ឬកាលៈទេសៈមិនអំណោយផល ។
- ក្នុងករណីមានការចាំបាច់តាមការសម្រេចរបស់នាយករដ្ឋមន្ត្រី ដែលត្រូវផ្ដល់ប្រាក់បុរេប្រទានសម្រាប់អនុវត្តគម្រោងក្នុងក្របខ័ណ្ឌនៃឥណទានឆ្នាំបន្ទាប់ ក្រសួង-ស្ថាប័នត្រូវកាត់ទុកកញ្ចប់ឥណទាននៃឆ្នាំបន្ទាប់សម្រាប់អនុវត្តគម្រោងនេះ ។

មាត្រា៦.

ចំពោះការផ្ដល់ប្រាក់បុរេប្រទានសម្រាប់អនុវត្តគម្រោងវិនិយោគសាធារណៈ ដែលហិរញ្ញប្បទានដោយដៃគូរអភិវឌ្ឍន៍ត្រូវអនុវត្តតាមស្មារតីអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៧ ។

មាត្រា៧.

ការអនុវត្តផ្ដល់ប្រាក់បុរេប្រទានតាមរយៈមូលប្បទានប័ត្រសម្រាប់ចំណាយទៅចូលរួមការប្រជុំអាស៊ាននៅបរទេស ត្រូវឆ្លងកាត់មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ

ដើម្បីកាត់ទុកឥណទានថវិកា សម្រាប់ធ្វើការទូទាត់ក្រោយពេលគណៈប្រតិភូវិលត្រឡប់ពីបរទេសវិញ ។

ជំពូកទី ៣
កិច្ចដំណើរការនៃការផ្តល់ប្រាក់បុរេប្រទាន

មាត្រា៨.

ចំពោះការចំណាយទិញសម្ភារៈបរិក្ខារសម្រាប់ការប្រឡងប្រជែង ការប្រកួតកីឡា និងពិធីផ្សេងៗដែលមានចំនួនទឹកប្រាក់ចាប់ពី <u>ហាសិបលានរៀល</u> ឡើងទៅ មិនអនុញ្ញាតឱ្យធ្វើការផ្តល់បុរេប្រទានថវិកាទេ ។ ក្រសួង-ស្ថាប័នត្រូវលើកសំណើសុំធានាចំណាយដោយឡែកដើម្បីអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ ហើយការចេញអាណត្តិបើកប្រាក់ក្រោយពីការប្រគល់-ទទួលទំនិញតាមកិច្ចសន្យា ។

មាត្រា៩.

ការផ្តល់ប្រាក់បុរេប្រទាន (ឬការផ្តល់ថវិកាមួយចំនួនមុនសម្រាប់ចំណាយដំណើរការ) ទាំងឡាយដូចបានកំណត់នៅក្នុងមាត្រា ៤ ត្រូវអនុវត្តដូចខាងក្រោមនេះ ÷

- ចំពោះចំណាយចរន្ត ត្រូវផ្តល់ថវិកាសម្រាប់ចំណាយដំណើរការមុនចំនួន ៦០% នៃទឹកប្រាក់ដែលត្រូវផ្តល់បុរេប្រទាន ។ លើកលែងតម្រោងសម្រាប់ចំណាយជួសជុល ថែទាំហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងធារាសាស្ត្រ ការផ្តល់ថវិកាសម្រាប់ចំណាយដំណើរការមុនត្រឹម ៤០% ។
- ចំពោះចំណាយថវិកាវិនិយោគ ត្រូវផ្តល់ប្រាក់បុរេប្រទានមិនលើសពី ៤០% នៃទឹកប្រាក់តម្រោងសម្រាប់ចំណាយវិនិយោគសាធារណៈ ។

មាត្រា១០.

ក្នុងករណីចំណាយប្រាក់បុរេប្រទាន ដែលទាក់ទងនឹងការផ្គត់ផ្គង់ទំនិញ សំណង់ និងសេវាត្រូវតែអនុវត្តតាមនីតិវិធីលទ្ធកម្មសាធារណៈដែលមានចែងជាធរមាន ។

មាត្រា១១.

អាណាប័កនៃក្រសួង ស្ថាប័ននានា ដែលបានបញ្ជាចំណាយថវិការបស់ខ្លួនតាមរយៈការផ្តល់ប្រាក់បុរេប្រទាននៅក្នុងក្របខ័ណ្ឌចំណាយថវិកាចរន្ត និងចំណាយថវិកាវិនិយោគសាធារណៈ ចាំបាច់ត្រូវបំពេញឱ្យបានគ្រប់គ្រាន់ និង

ត្រឹមត្រូវជាលាយលក្ខណ៍អក្សរនូវ " សលាកប័ត្រគណនេយ្យភាពហិរញ្ញវត្ថុ " ដើម្បីអមភ្ជាប់មកជាមួយនូវសំណើសុំប្រើប្រាស់សាច់ប្រាក់របស់ថវិកាជាតិតាមរយៈរូបភាពបុរេប្រទាននេះ ។

សលាកប័ត្រគណនេយ្យភាពហិរញ្ញវត្ថុខាងលើ ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

ជំពូកទី ៤
កិច្ចនិយ័តកម្មនៃប្រាក់បុរេប្រទាន

មាត្រា១២.

អាណាប័កគ្រប់ក្រសួង ស្ថាប័ន ត្រូវចាត់តាំងរដ្ឋទេយ្យករដែលមានស្រាប់ដើម្បីឱ្យទទួលបន្ទុកបន្ថែមក្នុងការតាមដានចំណាយថវិកា និងទទួលខុសត្រូវក្នុងការប្រមូលលិខិតយុត្តិការចំណាយថវិកា (សក្ខីប័ត្រចំណាយ) សម្រាប់រៀបចំធ្វើអាណត្តិនិយ័តកម្ម និងអាណត្តិបើកប្រាក់បង្គ្រប់ទៅតាមចំនួនទឹកប្រាក់ដែលបានកំណត់នៅក្នុងលិខិតបុរេប្រទានថវិកា ។

មាត្រា១៣.

រាល់លិខិតយុត្តិការចំណាយ ត្រូវមានចុះហត្ថលេខាបញ្ជាក់ទទួលស្គាល់ពីភាពត្រឹមត្រូវរបស់អាណាប័ក ឬមន្ត្រីដែលមានការប្រគល់សិទ្ធិជំនួស ។

មាត្រា១៤.

នីតិវិធីនៃការផ្តល់ប្រាក់បុរេប្រទាន ដូចមានបទប្បញ្ញត្តិចែងក្នុងមាត្រាទាំងឡាយនៃអនុក្រឹត្យនេះ ត្រូវមានការណែនាំលម្អិតសម្រាប់អនុវត្តជាក់ស្តែងដោយសារាចរ ឬប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ជំពូកទី ៥
អវសានប្បញ្ញត្តិ

មាត្រា១៥.

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា១៦.

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ស្ថាប័ន រដ្ឋលេខាធិការគ្រប់រដ្ឋលេខាធិការដ្ឋាន ត្រូវអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៩

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- អាជ្ញាធរសវនកម្ម
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១៦
  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

បានយកសេចក្តីជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៣៧[illegible]. អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងព័ត៌មាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងព័ត៌មាន

ស ម្រេ ច

មាត្រា ១ : ត្រូវបានតែងតាំងលោក **ឈិន ឈាង** ជាទីប្រឹក្សាក្រសួងព័ត៌មាន មានឋានៈស្មើ **អគ្គនាយករង** ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងព័ត៌មាន រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និង សាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៩

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច ✓*
- *ឯកសារ_កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៣៧៧ - អនក្រ.តត

អនុក្រឹត្យ

ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ [illegible] ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ១០៩៦ អនក្រ.តត ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០៨ ស្តីពីការ[illegible] ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមតម្រូវការការងារចាំបាច់

សម្រេច

មាត្រា ១ : តែងតាំងលោកស្រី **សេង សុផល** ជាជំនួយការសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន [illegible] នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ ប្រធាននាយកដ្ឋាន បន្ថែមលើមុខងារបច្ចុ[illegible]

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួង[illegible] រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន[illegible] និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ [illegible]

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:១៣៧៧ . អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយសហមេត្រី

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយសហមេត្រី** តាមលំដាប់ថ្នាក់ ជូនឥស្សរជនបរទេស ចំនួន០៣រូប ដែលមានស្នាដៃល្អ និងគុណបំណាច់ខ្ពស់ ក្នុងកិច្ចសហប្រតិបត្តិការជួយអភិរក្សសត្វព្រៃ និងអភិវឌ្ឍន៍ការងារចិញ្ចឹមសត្វ នៅព្រះរាជាណាចក្រកម្ពុជា ដូចមានរាយនាមខាងក្រោយ :-

ក_ មេដាយសហមេត្រី ថ្នាក់ សេនា :

១-លោកស្រីបណ្ឌិត **Jennifer Catherin Daltry** អតីតប្រធានអង្គការសត្វព្រៃ និងរុក្ខជាតិអន្តរជាតិ **Fauna & Flora International** បច្ចុប្បន្នជាអ្នកជំនាញជីវវិទ្យាជាន់ខ្ពស់ ប្រចាំកម្មវិធីអភិរក្សក្រពើនៅកម្ពុជា ។

២-លោកស្រីបណ្ឌិត **Barbara Maas** ប្រធានអង្គការ **Care for the Wild Internatinal** ប្រចាំប្រទេសអង់គ្លេស ។

ខ_ មេដាយសហមេត្រី ថ្នាក់ អស្សឫទ្ធិ :

-លោក **Dirk Van Aken** ប្រធានក្រុមជំនួយការបច្ចេកទេស នៃគម្រោងចិញ្ចឹមសត្វកម្ពុជា-សហគមន៍អឺរ៉ុប (**SLPP**) ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវអនុវត្តអនុក្រឹត្យ នេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ [illegible] ឆ្នាំ ២០០៩

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៣៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការបន្ថែមសមាសភាពគណៈកម្មការជាតិរៀបចំគោលការណ៍ណែនាំ និងនីតិវិធី ក្នុងការដឹកនាំ ការការពារសារណា និងនិក្ខេបបទ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៧៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៩ ស្តីពីការបង្កើតគណៈកម្មការជាតិរៀបចំគោលការណ៍ណែនាំ និងនីតិវិធីក្នុងការដឹកនាំ ការការពារសារណា និងនិក្ខេបបទ
- តាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

សម្រេច

មាត្រា១.-

បន្ថែមសមាសភាពគណៈកម្មការជាតិរៀបចំគោលការណ៍ណែនាំ និងនីតិវិធី ក្នុងការដឹកនាំ ការការពារសារណា និងនិក្ខេបបទ ដែលមានរាយនាមដូចខាងក្រោម៖

១- ឯកឧត្តម **ពិត ចំណាន**	រដ្ឋលេខាធិការក្រសួងអប់រំយុវជន និងកីឡា	**អនុប្រធាន**
២- លោកជំទាវ បណ្ឌិត **តឿង សគុណា**	រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា	**អនុប្រធាន**
៣- លោកជំទាវ បណ្ឌិត **ខ្លូត ធីតា**	ប្រធានរាជបណ្ឌិតសភាកម្ពុជា	**អនុប្រធាន**
៤- ឯកឧត្តម បណ្ឌិត **នេត បារ៉ុម**	អនុប្រធានរាជបណ្ឌិតសភាកម្ពុជា	**សមាជិក**
៥- ឯកឧត្តម បណ្ឌិត **ប៊ុច សុវត្ថិ**	សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ	**សមាជិក**

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ប្រធានគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ប្រធានរាជបណ្ឌិតសភាកម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែ កញ្ញា ឆ្នាំ ២០០៩

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៣៤០ . អនក្រ . បក

អនុក្រឹត្យ
ស្តីពី
ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ,
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ /នស / ៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការ រៀបចំ និងការប្រព្រឹត្តទៅនៃ គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/ រកម / ០១៩៦ / ០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យ លេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យ លេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែកញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តនីតិវិធី ការផ្លាស់ប្តូរ ក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

សម្រេច

មាត្រា ១ : ត្រូវបានប្រគល់ភារកិច្ចជូនលោក ឡើម ចន្ទូ អនុមន្ត្រីលេខ ១១ ឱ្យបំពេញមុខងារជា ប្រធាននាយកដ្ឋាន សវនកម្មផ្ទៃក្នុង នៃក្រសួងឧស្សាហកម្មរ៉ែនិងថាមពល ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ
- រាជកិច្ច

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៣៧១ . អនក្រ . តត

អនុក្រឹត្យ
ស្តីពី
ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា.
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ /នស / ៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/ រកម / ០១៩៦ / ០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យ លេខ ៣៥ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យ លេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែកញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តនី ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើររបស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

សម្រេច

មាត្រា ១ : ត្រូវបានប្រគល់ភារកិច្ចជូនលោក **គង់ សាំងហេង** អនុមន្ត្រីលេខ១៣ ឱ្យបំពេញមុខងារជាអគ្គាធិការរង នៃអគ្គាធិការដ្ឋានរបស់ក្រសួងឧស្សាហកម្មរ៉ែនិងថាមពល ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០០៩ .

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ
- រាជកិច្ច

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៣៨៧ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូនមន្ត្រីបច្ចេកទេស និងសប្បុរសជន ចំនួន១០រូប ដែលមានស្នាដៃល្អ និងគុណបំណាច់ក្នុងការអភិវឌ្ឍន៍លើវិស័យព្រះពុទ្ធសាសនា ដោយបានយកអស់កំលាំងកាយ-ចិត្ត ចំណេះដឹង និងចូលរួមយ៉ាងសកម្មខាងផ្នែកបច្ចេកទេសក្នុងការកសាងព្រះពុទ្ធរូបទ្រង់ឈរមួយអង្គ ដែលមានកំពស់ ១៣,៥០ម៉ែត្រ សម្រាប់តម្កល់នៅលើកំពូលភ្នំ ជីតាពេជ្រ ភូមិវត្តភ្នំ ឃុំកំពែង ស្រុកគីរីវង់ ខេត្តតាកែវ ដូចមានរាយនាមខាងក្រោម :-

១-លោក គង់ ប៊ុលីន	៦-អ្នកស្រី ញឹម ឈុនហេង
២-លោក ម៉េង សេរីវុឌ្ឍ	៧-អ្នកស្រី ស៊ិន ហួន
៣-លោក លឹម ត្រី	៨-អ្នកស្រី ពៅ ទ៉ៅ
៤-លោក ម៉ិន ណារ៉ា	៩-លោក ឈួ ចក់
៥-លោក ហុង សំអាង	១០-លោក ឃៀង សេង

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងអភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៣៨៣ អនក្រ.តត

អនុក្រឹត្យ
ស្តីពី
ការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាល ប្រចាំសាលាជាតិកសិកម្មកំពង់ចាម

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១១១ អនក្រ.បក ចុះថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០០១ ស្តីពីការបង្កើតសាលាជាតិកសិកម្មកំពង់ចាម ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

សម្រេច

មាត្រា ១ : ត្រូវបានតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាល ប្រចាំសាលាជាតិកសិកម្មកំពង់ចាម សម្រាប់អាណត្តិទី ៣ ដែលមានសមាសភាពដូចខាងក្រោម :

១-	ឯកឧត្តម **សាន វណ្ណធី**	តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	ប្រធាន
២-	លោកស្រី **ឆាយ សំនៀង**	តំណាងទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក

៣-	លោក	**មាស ចាន់ដេត**	តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
៤-	លោក	**គីម អឿន**	តំណាងក្រសួងអប់រំ យុវជន និងកីឡា	សមាជិក
៥-	លោក	**ឈាត សំណាង**	តំណាងក្រសួងអភិវឌ្ឍន៍ជនបទ	សមាជិក
៦-	លោក	**ម៉ី លីហ្មត**	តំណាងក្រសួងធនធានទឹក និងឧតុនិយម	សមាជិក
៧-	លោក	**យិន ចន្ថា**	តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ	សមាជិក
៨-	លោក	**ហៃ ខួនលី**	តំណាងអភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម	សមាជិក
៩-	លោក	**សំ សារិន**	នាយកសាលាជាតិកសិកម្មកំពង់ចាម	សមាជិកស្ម័យប្រវត្តិ
១០-	លោក	**វ៉ន មុនិន្ទ**	តំណាងសាកលវិទ្យាល័យភូមិន្ទកសិកម្ម	សមាជិក
១១-	លោក	**ស្រ៊ុន ហេង**	តំណាងបុគ្គលិកសាលាជាតិកសិកម្មកំពង់ចាម	សមាជិក

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា អភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៣០៧ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យ លេខ ៦៦ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

សម្រេច

មាត្រា ១ : តែងតាំងលោក **លី សំអាន** ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ជំនួសលោក **ញាន ស្រស់** ដែលត្រូវបានដាក់ឱ្យចូលនិវត្តន៍ ។

មាត្រា ២ : រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាម៉ីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៩

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៣៨៥ អនក្រ.តត

អនុក្រឹត្យ
ស្តីពី
ការតម្លើងឋានន្តរស័ក្តិមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥១ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់
- យោងតាមសំណើរបស់រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

សម្រេច

មាត្រា ១ : ត្រូវបានតម្លើងឋានន្តរស័ក្តិលោក **យស់ នោមណារ៉ាឌី** ពី មន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ៨ ទៅមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៩ នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ នៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ ១០ ឆ្នាំ ២០០៩

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល</u> :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា "២"
- រាជកិច្ច ✓
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៣៧៦..អនក្រ-បក

អនុក្រឹត្យ
ស្តីពី
ការជូន គ្រឿងឥស្សរិយយស

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ។
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា ។
- តាមសំណើរបស់សម្តេចចៅហ្វាវាំង គង់ សំអុល ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង និងជាប្រធានគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ ។

សម្រេច

មាត្រា ១ : បំពាក់ **គ្រឿងឥស្សរិយយស** តាមប្រភេទ និង លំដាប់ថ្នាក់ ជូនមន្ត្រីរាជការ និងកងកំលាំងប្រដាប់អាវុធ ចំនួន ៨៨ រូប ដែលបានរួមសហការល្អក្នុងការរៀបចំព្រះរាជពិធីបុណ្យទ្វាទសមាស បុណ្យជាតិ-អន្តរជាតិ និងពិធីទទួល ជូនគណៈប្រតិភូជាន់ខ្ពស់ជាតិ-អន្តរជាតិ ដូចមានរាយនាមខាងក្រោម :

ក. មេដាយមាសការងារ :

១- លោក	ទេព សុចណ្ណ	២- លោក	លួយ ខ្សែម
៣- លោក	សេង រតនៈ	៤- លោក	សយ គា
៥- លោក	ផេង ជា	៦- លោកស្រី	កែច ដានី
៧- លោក	និន សុខស្តី	៨- លោក	ប៉ូយ លាប
៩- លោកស្រី	សេកខាំ សាថន	១០- លោក	អ៊ូប សុចណ្ណ
១១- លោក	សោម ថុន	១២- លោក	គង់ ប៊ុនសិទ្ធ

១៣- លោក	សៃ ប៊ុនថន	១៤- លោក	ឡឹក ឿង
១៥- លោក	ស៊ុំ សាធឿន	១៦- លោក	អ៊ុម យន់ថន
១៧- លោក	ហង់ រិទ្ធី	១៨- លោក	ប៉ែន សោម
១៩- លោក	ឌី ដាវិន	២០- លោក	គីម ផាន់និត
២១- លោក	សរ ដាវិន	២២- លោក	ស្រេង រដ្ឋា
២៣- លោក	អ៊ុន សុខា	២៤- លោក	អ៊ុង សៅឌី
២៥- លោក	អ៊ុង សាឌុន	២៦- លោកស្រី	ឈួ សុខឡេង
២៧- លោក	ឆោង សារុន	២៨- លោក	ប៉ែន សំអឿន
២៩- លោក	ប្រាក់ សាមិត្ត	៣០- លោក	ហង់ ទូច
៣១- លោក	អ៊ុក ចំរើន	៣២- លោក	ភួន ចន្ថា
៣៣- វរសេនីយ៍ត្រី	តួច ប៊ុនណា	៣៤- លោក	ដាយ ប៉ែន
៣៥- អនុសេនីយ៍ឯក	ណេត ប៊ុនធឿន	៣៦- លោក	ចាន់ ប៊ុនណេត
៣៧- អនុសេនីយ៍ទោ	ឆន ធឿន	៣៨- អនុសេនីយ៍ទោ	ព្រាប ខា
៣៩- អនុសេនីយ៍ទោ	ផៅ សុធា	៤០- អនុសេនីយ៍ត្រី	នូ ទូច
៤១- អនុសេនីយ៍ត្រី	ឡុត សេរីបុត្រ	៤២- អនុសេនីយ៍ត្រី	ជួន វិចិត្រ
៤៣- អនុសេនីយ៍ត្រី	សួស សុខុម	៤៤- អនុសេនីយ៍ត្រី	ចេង សុភី
៤៥- អនុសេនីយ៍ត្រី	ព្រុំ ផេង	៤៦- អនុសេនីយ៍ត្រី	អឿម ណាត
៤៧- អនុសេនីយ៍ត្រី	ភួង មុន្នីវីរៈ	៤៨- អនុសេនីយ៍ត្រី	យស់ ចិន្តារិទ្ធី
៤៩- អនុសេនីយ៍ត្រី	នឹម ចណ្ណៈ	៥០- ព្រិន្ទបាលឯក	មឿន សម្បត្តិ
៥១- ព្រិន្ទបាលទោ	ថេង រ៉ាលី	៥២- នាយចំណង់	គង់ ចណ្ណា

២- មេដាយប្រាក់ការងារ :

១- លោក	ឈឹម រចនា	២- លោក	ស៊ុត ចណ្ណា
៣- លោកស្រី	មី ប៊ុនស៊ុំ	៤- លោកស្រី	កែប សម្បត្តិ
៥- លោក	ណោ ឡាដាំង	៦- លោកស្រី	សួង ចន្ថា
៧- លោក	មាស សុឃី	៨- លោក	នូ ហ៊ាន់
៩- លោក	គីម ចន្ទ្រា	១០- លោក	ផាត់ រី
១១- លោក	លឿង តារា	១២- អ្នកស្រី	នួន ដាវី
១៣- លោក	សេក សារ៉ាត់	១៤- លោក	គីម រ៉ាវី
១៥- លោក	អើត សុបិន្តបណ្ឌិត	១៦- លោក	ហ៊ិត សាលី
១៧- លោក	គា យូខេង	១៨- លោក	មាន ប៊ុណ្ណា
១៩- លោក	ប៊ិច ប៊ុន្នី	២០- អនុសេនីយ៍ត្រី	រ័ត្ន ពៅ
២១- អនុសេនីយ៍ត្រី	សោម ប៊ុនថេរ	២២- អនុសេនីយ៍ត្រី	សាម ប៉ូលីនិត្យ
២៣- អនុសេនីយ៍ត្រី	ទេព សំណាង	២៤- ព្រិន្ទបាលឯក	សូត្រ រស់
២៥- ព្រិន្ទបាលឯក	ហួង ខេមរ៉ា		

គ_ មេដាយសេរីវឌ្ឍនភាពទោរ :

១- ព្រិន្ទបាលឯក សួខ ផា
២- ព្រិន្ទបាលឯក វ៉ា នីន
៣- ព្រិន្ទបាលទោ ឯម សាម៉េត
៤- ព្រិន្ទបាលទោ អ៊ុំ ព្រុំ
៥- ព្រិន្ទបាលទោ អ៊ួន អាព
៦- ព្រិន្ទបាលទោ ម៉ាន់ សារ៉េត
៧- ព្រិន្ទបាលទោ ស្តើង ផល្លា
៨- ពលបាលឯក សៃ គឹមសាន
៩- ពលបាលឯក ស្រី យ៉ាវ័ន្ត
១០- ពលបាលឯក យ៉ិត ចាន់ដារ៉ា
១១- ពលបាលឯក ហែម ផល្លី

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ - អន្តរជាតិ និងក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អប្រសើរ ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៣៤៧ . អនក្រ-ទត

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន០៦រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមជួយកសាងព្រះវិហារ នៅវត្តពោធិវិន័យ (ស្រះខាងកើត) ស្ថិតនៅឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ ដូចមានរាយនាមខាងក្រោម :-

ក-មេដាយមាសស្ថាបនាជាតិ :

១-ឧត្តមសេនីយ៍ត្រី **ស៊ូរ ចាន់ហេង** អត្តលេខ ០០០១៤៥ មេបញ្ជាការកងពលតូចលេខ ៥១ ថវិកាចំនួន ១០.៥០០ ដុល្លារ

២-លោក **ខៀវ សាវ៉ាត** សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកាចំនួន ១៥.០០០ ដុល្លារ

៣-លោក **គួល យ៉ា** សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកាចំនួន ១១.៥០០ ដុល្លារ

៤-លោក **ខឹម អឿម** សប្បុរសជននៅខេត្តបន្ទាយមានជ័យ ថវិកាចំនួន ១០.៣០០ ដុល្លារ

ខ-មេដាយសំរិទ្ធស្ថាបនាជាតិ :

១-លោក **នាង ធា** សប្បុរសជននៅខេត្តបន្ទាយមានជ័យ ថវិកាចំនួន ២.៥០០ ដុល្លារ

២-លោក **ហាយ ហឿន** សប្បុរសជននៅខេត្តបន្ទាយមានជ័យ ថវិកាចំនួន ២.១០០ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០... ខែ កញ្ញា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:១៣៨៧.អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន០៥រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមជួយកសាងផ្លូវ ជីកស្រះទឹក ទិញសំភារៈនិងស្បៀងផ្តល់ជូនប្រជាពលរដ្ឋក្រីក្រ នៅក្នុងឃុំតាបែន ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ដូចមានរាយនាមខាងក្រោម :-

ក_មេដាយប្រាក់ស្ថាបនាជាតិ :

១-លោក **ឈឿម សុផុន**	នៅខេត្តបន្ទាយមានជ័យ	ថវិកាចំនួន ៥.១៣០ ដុល្លារ
២-លោក **សៅ តេនា**	នៅខេត្តបន្ទាយមានជ័យ	ថវិកាចំនួន ៥.០៥០ ដុល្លារ

ខ_មេដាយសំរឹទ្ធស្ថាបនាជាតិ :

១-លោក **សន គឹមសួគ៌**	នៅខេត្តបន្ទាយមានជ័យ	ថវិកាចំនួន ១.៥៣០ ដុល្លារ
២-លោក **សួន នីប៉ូ**	នៅខេត្តបន្ទាយមានជ័យ	ថវិកាចំនួន ១.៥២០ ដុល្លារ
៣-លោក **កែវ សារិន**	នៅខេត្តបន្ទាយមានជ័យ	ថវិកាចំនួន ១.៥០០ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:១៣៧៩ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេននិងជូនសប្បុរសជន ចំនួន០៨រូប ដែលបានបរិច្ចាគបច្ច័យនិងថវិកា ចូលរួមជួយកសាងព្រះវិហារ និងសមិទ្ធផលផ្សេងៗលើវិស័យព្រះពុទ្ធសាសនា នៅវត្តធម្មារាម ឃុំរុងរឿង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ដូចមានរាយព្រះនាមនិងនាមខាងក្រោម :-

ក_មេដាយមាសស្ថាបនាជាតិ :

១-ព្រះគ្រូ	គីម សួរ	ព្រះចៅអធិការវត្ត	បច្ច័យចំនួន ១៦.០០០ ដុល្លារ
២-លោក	ជាម តោរសេន	សប្បុរសជន	ថវិកា ចំនួន ៤៣.៨៥០ ដុល្លារ
៣-លោក	សុខ យ៉ាន		ថវិកា ចំនួន ១៥.០០០ ដុល្លារ
៤-លោក	ម៉ក់ សារុទ្ធី	សប្បុរសជន	ថវិកា ចំនួន១៣.៧៤១ ដុល្លារ

ខ_មេដាយប្រាក់ស្ថាបនាជាតិ :

១-លោក	ម៉ើន យ៉ឺន	ថវិកា ចំនួន ៦.៦៥០ ដុល្លារ
២-លោក	ឈាង ឆាំង	ថវិកា ចំនួន ៦.៥៥០ ដុល្លារ
៣-លោក	យ៉ឹង យ៉ន	ថវិកា ចំនួន ៦.០៥០ ដុល្លារ
៤-ឧបាសិកា	ង៉ែត ម៉ាណាត់	ថវិកា ចំនួន ៥.១៣៤ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា និងអភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

ភ្នំពេញ ថ្ងៃទី ... ខែ កញ្ញា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៣៩០.អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និងជូនសប្បុរសជន ចំនួន ២៧រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងសមិទ្ធផលសាធារណៈផ្សេងៗក្នុងវិស័យព្រះពុទ្ធសាសនា អប់រំ គមនាគមន៍ និងធារាសាស្ត្រ នៅស្រុកជុំគីរី ខេត្តកំពត ដូចមានរាយព្រះនាមនិងនាមខាងក្រោម :-

ក_មេដាយមាសស្ថាបនាជាតិ :

១-ព្រះតេជគុណ	**ឯក**	**អ៊ុន**	ព្រះចៅអធិការវត្តអង្គចក	បច្ច័យ ចំនួន ១០.២០០ ដុល្លារ
២-អ្នកស្រី	**ស៊ឹម**	**វិល័យ**	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកា ចំនួន ២០.០០០ ដុល្លារ
៣-លោក	**ម៉ាន់**	**ស៊ីវណ្ណា**	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកា ចំនួន ១២.០០០ ដុល្លារ
៤-លោក	**ជ័យ**	**ឈាគី**	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកា ចំនួន ១១.៥០០ ដុល្លារ
៥-ឯកឧត្តម	**ឃុន**	**ទុធ**	អនុរដ្ឋលេខាធិការក្រសួងការពារជាតិ	ថវិកា ចំនួន ១០.៦០០ ដុល្លារ
៦-លោក	**អ៊ឹង**	**ម៉េងហួរ**	សប្បុរសជននៅខេត្តកំពត	ថវិកា ចំនួន ១០.២០០ ដុល្លារ
៧-លោក	**លឹម**	**ហ៊ុយឡេង**	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកា ចំនួន ១០.០០០ ដុល្លារ
៨-លោក	**អ៊ុក**	**សីហា**	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកា ចំនួន ១០.០០០ ដុល្លារ
៩-លោក	**ឆាំ**	**ម៉េងហុក**	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកា ចំនួន ១០.០០០ ដុល្លារ
១០-លោក	**ខិក**	**ប្រាក់**	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកា ចំនួន ១០.០០០ ដុល្លារ
១១-លោក	**លឹម**	**ឆាយ**	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកា ចំនួន ១០.០០០ ដុល្លារ

១២-លោក	ជ្រឹក	ម៉ុនធឿន	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកា ចំនួន ១០.០០០ ដុល្លារ
១៣-លោក	កែវ	ស៊ូភា	សប្បុរសជននៅខេត្តព្រះសីហនុ	ថវិកា ចំនួន ១០.០០០ ដុល្លារ
១៤-លោក	កែវ	ស៊ុនគិរី	សប្បុរសជននៅខេត្តព្រះសីហនុ	ថវិកា ចំនួន ១០.០០០ ដុល្លារ
១៥-លោក	ខួន	ម៉ុនណា	សប្បុរសជននៅខេត្តព្រះសីហនុ	ថវិកា ចំនួន ១០.០០០ ដុល្លារ
១៦-លោក	យឹម	អក្ខរា	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកា ចំនួន ១០.០០០ ដុល្លារ
១៧-លោក	សេង	ណារិន	សប្បុរសជននៅខេត្តព្រះសីហនុ	ថវិកា ចំនួន ១០.០០០ ដុល្លារ
១៨-លោក	គីម	សាវុធ	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកា ចំនួន ១០.០០០ ដុល្លារ
១៩-លោក	អ៊ុត	ធីរិទ្ធ	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកា ចំនួន ១០.០០០ ដុល្លារ
២០-លោក	ខែម	ឆាន់	សប្បុរសជននៅខេត្តកំពត	ថវិកា ចំនួន ១០.០០០ ដុល្លារ
២១-លោក	ចាន់	វណ្ណា	សប្បុរសជននៅខេត្តកំពត	ថវិកា ចំនួន ១០.០០០ ដុល្លារ
២២-លោក	លឹម	ផារឿន	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកា ចំនួន ១០.០០០ ដុល្លារ

ខ-មេដាយប្រាក់ស្ថាបនាជាតិ :

-លោក	គង់	ស៊ាន់	សប្បុរសជននៅខេត្តកំពត	ថវិកា ចំនួន ៥.០០០ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ២៣ កញ្ញា ឆ្នាំ ២០០៩

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:១៣៥៦.អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយសុវត្ថារា

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយសុវត្ថារា** តាមលំដាប់ថ្នាក់ ចំនួន ៤២ គ្រឿង ជូនមន្ត្រីរាជការ និងសប្បុរសជន ដែលបានខិតខំយកអស់កម្លាំងកាយ-ចិត្ត និងធនធានជួយអភិវឌ្ឍន៍ ភូមិ-ឃុំ ក្នុងស្រុកពាមរក៍ និងស្រុកពាមជរ ខេត្តព្រៃវែង ទទួលបានលទ្ធផលល្អប្រសើរ ដូចមានរាយនាមខាងក្រោម :-

ក_មេដាយសុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍ :

១-លោក	**ពត គ្រួច**	អនុប្រធាននាយកដ្ឋានក្រសួងមហាផ្ទៃ
២-លោក	**សុខ ថន**	អគ្គនាយករងក្រសួងទំនាក់ទំនងរដ្ឋសភាព្រឹទ្ធសភា និងអធិការកិច្ច
៣-លោក	**ឡុង ថាត**	អភិបាលស្រុកពារាំង
៤-លោក	**ចាន់ ដេត**	អភិបាលស្រុកពាមជរ
៥-លោក	**សៅ ប្រសិទ្ធ**	អភិបាលស្រុកពាមរក៍
៦-លោកស្រី	**ម៉េង ច័ាន់ដានីន**	មន្ត្រីសាលាស្រុក

ខ_មេដាយសុវត្ថារា ថ្នាក់ សេនា :

១-លោក	**គុយ ម៉ិនហេង**	មន្ត្រីជំនួយការ
២-លោក	**ទេព សម្បត្តិ**	មន្ត្រីសាលាស្រុក
៣-លោក	**ណុប គឹមសាន**	អនុប្រធានសាខាគយនិងរដ្ឋាករខេត្តព្រៃវែង
៤- លោក	**ម៉ក់ វ៉ន**	អនុប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត
៥-លោក	**ឈឹម សុវណ្ណឌឿន**	អភិបាលរងស្រុកពារក៍

គ_មេដាយសុវត្ថារា ថ្នាក់ អស្សឫទ្ធិ :

១-លោក	**សរិត មករា**	ប្រធានមន្ទីរផែនការ ខេត្តព្រៃវែង

២-លោក	ឈួន គឹមសាន	មេបញ្ជាការកងរាជអាវុធហត្ថស្រុកពាមរក៍
៣-លោក	គោរ សំណាង	មេបញ្ជាការកងរាជអាវុធហត្ថស្រុកពាមជរ
៤-លោក	សេង ពន្លក	អធិការនគរបាលស្រុកពាមរក៍
៥-លោក	នឹង ឈឿន	ប្រធានការិយាល័យសេដ្ឋកិច្ចស្រុកពាមរក៍
៦-លោក	ជា សំអុល	ប្រធានការិយាល័យអប់រំ ស្រុកពាមរក៍
៧-លោកស្រី	មាស សិទ្ធី	ប្រធានការិយាល័យកិច្ចការនារីស្រុកពាមរក៍
៨-លោក	ឈើន ហ៊ីន់	ប្រធានការិយាល័យកិច្ចការនារីស្រុកពាមជរ
៩-លោក	អ៊ូ រតនា	មេបញ្ជាការរងកងរាជអាវុធហត្ថស្រុកពាមរក៍
១០-លោកស្រី	ឆាំ សារិទ្ធ	មន្ត្រីអគ្គនាយកដ្ឋានពន្ធដារ
១១-លោក	យឹម សាគុណា	នគរបាលក្រសួងមហាផ្ទៃ
១២-លោក	សួរ ឌីម៉ា	សមាជិកក្រុមប្រឹក្សានីតិកម្មក្រសួងមហាផ្ទៃ
១៣-លោក	ម៉ៃ សាវុធ	មន្ត្រីសាលាស្រុក
១៤-លោក	គីម សុភាព	មន្ត្រីសាលាស្រុក
១៥-លោក	សោម សាម៉ន	នាយប៉ុស្តិ៍នគរបាលឃុំ ព្រែកខ្សាយ "ក"
១៦-លោក	យ៉ែន ពិន្ទុ	មន្ត្រីអាជ្ញាធរសវនកម្មជាតិ
១៧-លោក	ឈុត សៅ	មន្ត្រីរៀបចំដែនដី នគររូបនីកម្ម និងសំណង់
១៨-លោក	ម៉េត ចន្ទណា	នាយការិយាល័យទី៤ នៃភូមិភាគពិសេស
១៩-លោក	ខួច សំបូរ	មន្ត្រីនាយកដ្ឋានព័ត៌មាននៃរដ្ឋសភា
២០-លោក	សំ ស៊ីវត្ថា	មន្ត្រីជំនួយការ
២១-លោក	សំ ចាន់សុផល	មន្ត្រីជំនួយការ
២២-លោក	ហួន អេង	មន្ត្រីនាយកដ្ឋានព័ត៌មាននៃរដ្ឋសភា
២៣-លោក	ប្រាក់ ឆុល	មន្ត្រីនាយកដ្ឋានព័ត៌មាននៃរដ្ឋសភា
២៤-លោក	សោម អ៊ាង	អនុប្រធានមន្ទីរបរិស្ថាន/ហិរញ្ញវត្ថុខេត្ត
២៥-លោក	ស៊ិន សាគុណា	មន្ត្រីក្រសួងមហាផ្ទៃ
២៦-លោក	ញឹក ស៊ីផន	មន្ត្រីសាលាស្រុក
២៧-លោក	នង នីនាង	មន្ត្រីសាលាស្រុក
២៨-លោក	ពៅ លីមមី	មន្ត្រីសាលាស្រុក
២៩-លោក	ចេង សុវណ្ណ	មន្ត្រីសាលាស្រុក
៣០-លោក	ត្រាំ វឿង	មន្ត្រីសាលាស្រុក
៣១-លោក	គីម សីហា	អនុប្រធានការិយាល័យក្រសួងការពារជាតិ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៩

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៣៩៧ . អនក្រ . បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ចំនួន ១៨៧ គ្រឿង ជូនមន្ត្រីរាជការ ចំនួន ១៨៧រូប ដែលបានខិតខំយកអស់កម្លាំងកាយ-ចិត្ត ចុះជួយអភិវឌ្ឍន៍ ភូមិ-ឃុំ ក្នុងស្រុកពាមរក៍ និង ស្រុកពាមជរ ខេត្តព្រៃវែង ទទួលបានលទ្ធផលល្អប្រសើរ ដូចមានរាយនាមខាងក្រោម :-

ក. មេដាយមាសការងារ :

១-លោកស្រី	ឌី ស៊ីណាត	មន្ត្រីសាលាស្រុក
២-លោក	មាស ស៊ីនហាក់	ប្រធានមណ្ឌលសុខភាពស្រុកពាមរក៍
៣-លោក	ឈុំ ឈួន	ប្រធានមន្ទីស្រុកពាមរក៍
៤-លោក	សុខ ហុង	មេបញ្ជាការរងកងរាជអាវុធហត្ថស្រុកពាមរក៍
៥-លោក	វង្ស ណុល	អនុប្រធានការិយាល័យស្រុកពាមរក៍
៦-លោក	ឃុន ធីម	នាយកវិទ្យាល័យពាមរក៍
៧-លោកស្រី	សេង ទៀង	ប្រធានការិយាល័យរដ្ឋបាលទូទៅស្រុកពាមរក៍
៨-លោក	ហាស់ សុធន់	មន្ត្រីកសិកម្មស្រុកពាមរក៍
៩-លោក	ទូន ឈាន	មន្ត្រីសាលាស្រុក
១០-លោក	គួ រ៉ៃ	មន្ត្រីសាលាស្រុក
១១-លោកស្រី	ប្រាក់ ហឿន	មន្ត្រីរដ្ឋសភា
១២-លោក	ធន់ សុខាន់	មន្ត្រីការិយាល័យកសិកម្មស្រុកពាមរក៍
១៣-លោក	ចាន់ សុផល	អធិការរងនគបាលស្រុកពាមរក៍
១៤-លោក	ឡុង ម៉ៃ	អធិការរងនគបាលស្រុកពាមរក៍

១៥-លោក	គ្រួច ផានិត	អធិការរងនគរបាលស្រុកពាមរក៍
១៦-លោក	អ៊ុន សុផានណារិទ្ធ	អធិការរងនគរបាលស្រុកពាមរក៍
១៧-លោក	ប៊ិន ម៉ារី	អធិការរងនគរបាលស្រុកពាមរក៍
១៨-លោក	ម៉ែន វ៉ន់	នាយប៉ុស្តិ៍នគរបាលឃុំ ព្រែកល្ពៀង
១៩-លោក	អ៊ុំ គឹមសាន	នាយប៉ុស្តិ៍នគរបាលឃុំ បាបោង
២០-លោក	យ៉ង ស៊ីងួន	នាយប៉ុស្តិ៍នគរបាលឃុំ ពាមរក៍
២១-លោក	ស៊ិន ស៊ីហ៊ិន	នាយប៉ុស្តិ៍នគរបាលឃុំ ព្រែកខ្សាយ "ខ"
២២-លោក	ជិន សុផល	នាយប៉ុស្តិ៍នគរបាលឃុំ អ្នកលឿង
២៣-លោក	ជូ សារុន	នាយប៉ុស្តិ៍នគរបាលឃុំ បន្ទិចប្រាសាទ
២៤-លោក	រស់ ស៊ិន	នាយប៉ុស្តិ៍នគរបាលឃុំ ពាមមានជ័យ
២៥-លោក	ផាន់ ច័ន្ទកោសី	មេបញ្ជាការរងវីរអន្តរាគមរាជអាវុធហត្ថខេត្តព្រៃវែង
២៦-លោក	ឡោ ចេត	មន្ត្រីរដ្ឋសភា
២៧-លោក	ហ៊ួន ម៉ៅ	ជំនួយការឃុំព្រែកខ្សាយ "ត"
២៨-លោក	ស៊ុន យឹម	សមាជិកក្រុមប្រឹក្សា ឃុំព្រែកសំបួរ
២៩-លោក	ទូន សុគន្ធ	អនុប្រធានមន្ទីរហិរញ្ញវត្ថុខេត្ត
៣០-លោក	ឡាច សាខន	អនុប្រធានមន្ទីរផែនការខេត្ត
៣១-លោក	ប៉ា វ៉ន	អធិការរងស្រុកពាមជរ
៣២-លោក	សេង សុផា	អធិការរងស្រុកពាមជរ
៣៣-លោក	ភា ស៊ីនឿន	អធិការរងស្រុកពាមជរ
៣៤-លោក	ចាន់ សំណាង	អធិការរងស្រុកពាមជរ
៣៥-លោក	ញឹក នៅ	មេបញ្ជាការសឹករងស្រុកពាមជរ
៣៦-លោក	នួន ម៉េង	មេឃុំឫស្សីស្រុក
៣៧-លោក	ឡេង សាត	មេបញ្ជាការរងរាជអាវុធហត្ថស្រុកពាមជរ
៣៨-លោក	ស្បោង ពៅ	មេបញ្ជាការរងរាជអាវុធហត្ថស្រុកពាមជរ
៣៩-លោក	ខាត់ សាឃឿន	ប្រធានការិយាល័យអប់រំស្រុក
៤០-លោក	ផេង ហួរ	មេឃុំព្រែកក្របៅ
៤១-លោក	ជា បូណា	ប្រធានការិយាល័យសង្គមកិច្ចស្រុកពាមជរ
៤២-លោក	អ៊ឹម នី	ប្រធានមណ្ឌលសុខភាពស្វាយភ្លោះ
៤៣-លោក	ឌី ពិសិដ្ឋ	ប្រធានការិយាល័យស្រុក
៤៤-លោក	ឆេង ម៉ុន	ប្រធានការិយាល័យលទ្ធកម្ម នៃមន្ទីរហិរញ្ញវត្ថុខេត្ត
៤៥-លោក	ម៉ី សុត្ថា	ប្រធានការិយាល័យរៀបចំដែនដីស្រុកពាមជរ
៤៦-លោក	ស៊ូ រីណា	ប្រធានការិយាល័យសេដ្ឋកិច្ចស្រុកពាមជរ
៤៧-លោក	ព្រីង ហ៊ួរ	មេឃុំព្រែកសំបួរ
៤៨-លោក	ភេ អ៊ឹម	ប្រធានស្នាក់ការច្រកទ្វារតំបន់កោះសំពៅ
៤៩-លោកស្រី	កែប ច័ន្ទគន្ធា	មន្ត្រីជំនួយការគណៈកម្មការទី២ នៃរដ្ឋសភា
៥០-លោកស្រី	នួន មុំ	មន្ត្រីសាលាស្រុក
៥១-លោក	ឆាំ ឆោម	មន្ត្រីសាលាស្រុក
៥២-លោក	ថោង វណ្ណឌី	មន្ត្រីសាលាស្រុក
៥៣-លោក	សៀង សេង	មន្ត្រីសាលាស្រុក
៥៤-លោក	ឃួច លីនឌី	មន្ត្រីសាលាស្រុក
៥៥-លោក	ស៊ាន សេនា	មន្ត្រីសាលាស្រុក

៥៦-លោក	សា លាង	មន្ត្រីសាលាស្រុក
៥៧-លោក	ស៊ូ ម៉េង	មន្ត្រីរដ្ឋសភា
៥៨-លោក	នុត សារ៉េន	មន្ត្រីសាលាស្រុក
៥៩-លោក	ពេជ្រ ម៉ម	មន្ត្រីសាលាស្រុក
៦០-លោក	វេន ថូរ	មន្ត្រីសាលាស្រុក
៦១-លោក	អ៊ិច ហ៊ាន	មន្ត្រីសាលាស្រុក
៦២-លោក	ទា សុខឡេង	មន្ត្រីសាលាស្រុក
៦៣-លោក	ឡុង នឿន	មន្ត្រីសាលាស្រុក
៦៤-លោក	ណុំ វីរៈ	មន្ត្រីសាលាស្រុក
៦៥-លោក	យឹម សុងលីន	មន្ត្រីសាលាស្រុក
៦៦-លោក	យឹម វឌ្ឍនៈ	មន្ត្រីសាលាស្រុក
៦៧-លោក	ម៉ៅ សុខា	មន្ត្រីសាលាស្រុក
៦៨-លោក	ថាំង ស៊ីនវ៉េង	មន្ត្រីសាលាស្រុក
៦៩-លោក	អេង ធាក់	ប្រធានមន្ទីរទេសចរណ៍ខេត្ត
៧០-លោក	លី មុនីនាថ	ប្រធានមន្ទីរទេសចរណ៍ខេត្ត
៧១-លោក	ស៊ឹម សុវុទ្ធា	អនុប្រធានធានាគារជាតិខេត្ត
៧២-លោក	នូ គា	មន្ត្រីពន្ធធានាគារខេត្ត
៧៣-លោក	សេង សាវុធ	ប្រធានការិយាល័យខេត្ត
៧៤-លោក	ទូន ឈាន	អនុប្រធានស្នាក់ការបក្សស្រុក
៧៥-លោក	ហ៊ឹម ឡាញ	ប្រធានសាលាពន្ធដារស្រុក
៧៦-លោក	ពេជ្រ នៅ	មេបញ្ជាការផ្នែកសឹករងស្រុក
៧៧-លោក	ប៊ី ប៊ីន	មន្ត្រីការិយាល័យសាធារណៈការស្រុក
៧៨-លោក	ហែម រិទ្ធ	សមាជិកក្រុមប្រឹក្សាឃុំ
៧៩-លោក	ខែម ឃួន	ប្រធានមន្ទីរស្រុក
៨០-លោក	សួន សារ៉ាត	អធិការនគរបាលស្រុក
៨១-លោក	សេក សេរីវុឌ្ឍី	មេបញ្ជាការរងផ្នែកសឹករងស្រុក
៨២-លោក	ចក់ ថន	មេឃុំក្រាំងតាយ៉ង
៨៣-លោក	នួន សុគន្ធ	អនុប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត
៨៤-លោក	យាន មាត	អភិបាលរងស្រុក
៨៥-លោក	ឆែម ស៊ីនរដ្ឋា	មន្ត្រីការិយាល័យកំណត់ហេតុពិស្តារនៃរដ្ឋសភា
៨៦-លោក	មិ សំអុល	អនុប្រធាននាយកដ្ឋានក្រសួងមហាផ្ទៃ
៨៧-លោក	ចេង វុត្ថា	ប្រធានសន្តិសុខមន្ទីរពេទ្យកាល់ម៉ែត
៨៨-លោក	គ្រី សាន	មេឃុំស្វាយភ្លោះ
៨៩-លោក	ម៉ិល គីរី	មេឃុំកោះចេក
៩០-លោក	ស្រី ហ៊ួន	មេឃុំកោះរកា
៩១-លោក	ព្រាប ហឿន	មេឃុំកោះសំពៅ
៩២-លោក	ទុំ សារ៉េត	មេឃុំកំពង់ប្រាសាទ
